# ស្ថានភាពអតិផរណានៅខែមករា ឆ្នាំ២០១៩

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា នៅខែមករា ឆ្នាំ២០១៩នេះ ជារួម សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខនៅរាជធានីភ្នំពេញ ***ពុំមានការប្រែប្រួលទេបើធៀបនឹងខែមុន ប៉ុន្តែបានកើនឡើង ១,៥% បើធៀបនឹងខែមករាឆ្នាំមុន។***

នៅខែមករា ឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើន នៅរក្សាលំនឹង និងមានការប្រែប្រួលតិចតួចបើធៀបនឹងខែធ្នូ ឆ្នាំ២០១៨ កន្លងទៅ ជាពិសេស សន្ទស្សន៍ថ្លៃអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង សម្លៀកបំពាក់ និងស្បែកជើង និងការសិក្សា។

ប៉ុន្តែ បើប្រៀបធៀបនឹងខែមករាឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនមានការកើនឡើង ក្នុងនោះ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់បានកើនឡើង ៦,៤% (ស្រា និងថ្នាំជក់) សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន ៥,៨% និងសម្លៀកបំពាក់និងស្បែកជើង ២,៥%។ *ចំណែកឯ សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានធ្លាក់ចុះ ៥,៧% ក្នុងនោះ សន្ទស្សន៍ថ្លៃប្រេងសាំងធម្មតាធ្លាក់ចុះ ១៨,៦% និងសន្ទស្សន៍ថ្លៃប្រេងម៉ាស៊ូតធ្លាក់ចុះ ១២,៩%។* ជាក់ស្តែង ប្រេងសាំងធម្មតាលក់រាយលើទីផ្សារក្នុងខែមករា ឆ្នាំ២០១៩ ថ្លៃ ៣.៣០០ រៀល/លីត្រ ទាបជាងក្នុងខែដូចគ្នាឆ្នាំ២០១៨ ថ្លៃ ៣.៩៥០ រៀល/លីត្រ *(ប្រភព÷ Ministry of Commerce)*។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **០,០** | **+១,៥** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,១ | +២,១ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +១,២ | +៦,៤ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | ០,០ | +២,៥ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -០,១ | +០,៣ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +១,២ | +១,៤ |
| ៦-សុខាភិបាល | +០,២ | +២,៣ |
| ៧-ការដឹកជញ្ជូន | -២,៨ | -៥,៧ |
| ៨-គមនាគមន៍ | +០,៣ | -០,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | +០,៣ | +១,៤ |
| ១០-ការសិក្សា | ០,០ | +០,៤ |
| ១១-ភោជនីយដ្ឋាន | +១,២ | +៥,៨ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +០,១ | +០,៤ |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | ២០១៩ | ២០១៨ | | ២០១៩ |
| | វិច្ឆិកា | ធ្នូ | មករា | វិច្ឆិកា | ធ្នូ | មករា |
| អង្ករ | -0,៣ | +0,៣ | +0,២ | +២,៣ | +២,៤ | +២,៦ |
| សាច់គោ | 0,0 | +0,២ | +0,៤ | +១,៨ | +១,២ | +២,១ |
| សាច់មាន់ | +0,៤ | +0,៤ | +0,៥ | +២,១ | +៣,២ | +៤,0 |
| សាច់ទា | +0,៣ | -0,៣ | +0,៦ | +២,១ | +១,៥ | +២,២ |
| សាច់ជ្រូក | -១,៨ | -0,៣ | +0,៧ | +១,២ | +១,៥ | +១,៧ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | -0,៧ | +0,១ | +0,២ | +២,២ | +២,៣ | +២,៦ |
| ក្នុងនោះត្រីស្រស់ | -១,១ | +0,១ | 0,0 | +១,៧ | +១,៨ | +២,0 |
| ផ្លែឈើ | +0,១ | -0,៣ | -0,៧ | +៣,0 | +១,៨ | +១,៧ |
| ផ្លែឈើស្រស់ | +0,១ | -0,៣ | -0,៦ | +៣,0 | +១,៧ | +១,៦ |
| បន្លែ | -0,៩ | -0,៨ | -១,0 | +៤,៩ | +៣,៥ | +២,៧ |
| បន្លែជាស្លឹក | -១,៤ | -១,0 | -១,១ | +៧,៧ | +៤,៩ | +៥,១ |
| បន្លែជាផ្លែ | -0,៦ | -១,២ | -១,៥ | +៦,៤ | +៥,៤ | +២,៣ |

**កំណត់សម្គាល់**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមភាគធរណីមាត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)


***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:00 ដល់ ១១:00ព្រឹក និង ២:00 ដល់ ៥:00ល្ងាច*


*កំណត់សម្គាល់÷*


*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។ ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*